ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ...........................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១
## និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១០ របស់ធនាគារជាតិនៃកម្ពុជា

ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ នៅធនាគារជាតិនៃកម្ពុជា

សូមគោរព :

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីស្នេហា

មកដល់ពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារក្នុងឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១០ របស់យើង បានឈានដល់ទីបញ្ចប់ហើយ ។ ជារួម ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា សន្និបាតរបស់យើងបានប្រព្រឹត្តទៅយ៉ាងសកម្មរហូតដល់ទីបញ្ចប់ប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយនិងស្និទ្ធស្នាលជាទីបំផុត ។ ខ្ញុំជឿជាក់ថា សមាជិក-សមាជិកាទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសន្និបាតពេលនេះ ពិតជាក្តាប់បានពីសភាពការណ៍រួមនៃសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក និងលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន ខ្លឹមសារសំខាន់ៗ និងអនុសាសន៍ណែនាំនានា ដើម្បីយកទៅអនុវត្តការងារឲ្យចំទិសដៅ និងកាន់តែមានប្រសិទ្ធភាពថែមទៀត ។ លើសពីនេះទៀត អង្គសន្និបាតបានយល់ពីអត្ថន័យនៃការប្រារព្ធខួប៣០ឆ្នាំ នៃការបង្កើតធនាគារជាតិនៃកម្ពុជា និងការបោះផ្សាយប្រាក់រៀលដាក់ឲ្យចរាចរឡើងវិញផងដែរ ។

ខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ ដែលបានផ្តល់បទឧទ្ទេសនាម និងអនុសាសន៍ល្អៗជូនអង្គសន្និបាតយើង និងសូមថ្លែងអំណរគុណផងដែរចំពោះសមាជិក-សមាជិកានៃអង្គសន្និបាតទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គសន្និបាត និងបានខិតខំយកចិត្តទុកដាក់ស្តាប់ខ្លឹមសារនៃបទឧទ្ទេសនាម និងមានវត្តមានក្នុងអង្គសន្និបាតនេះតាំងពីដើមរហូតដល់ចប់ ។


ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបថា ពិភពលោកមិនស្ថិតនៅនឹងថ្កល់ទេ គឺវិវត្ត ទៅមុខជានិច្ច ក្នុងនោះក៏មានវិស័យនយោបាយនិងសេដ្ឋកិច្ចផងដែរ ។ ការប្រែប្រួលនេះ តែងតែនាំមកនូវផលល្អនិងផលអាក្រក់ ដែលតម្រូវឲ្យយើងចាត់វិធានការដោះស្រាយ ឲ្យបានសមស្របនិងទាន់ពេលវេលា ។ តាមការសិក្សាស្វែងយល់របស់ខ្ញុំ ខ្ញុំសង្កេតឃើញថា បច្ចុប្បន្នទស្សនវិស័យផ្នែកសេដ្ឋកិច្ចពិភពលោក មានការប្រែប្រួលដូចតទៅ ៖

១/- ការប្រែប្រួលផ្នែករូបសណ្ឋាន (Configuration) នៃសេដ្ឋកិច្ចនិងទីផ្សារហិរញ្ញវត្ថុ ពិភពលោក ដោយសារតែសេដ្ឋកិច្ចអាស៊ី គឺ ចិន ឥណ្ឌា និងប្រទេសអាស៊ីអាគ្នេយ៍ បានរក្សា កំណើនខ្ពស់ មានភាពរឹងមាំ និងនាំមុខគេក្នុងការជំរុញកំណើនសេដ្ឋកិច្ច ។ សេដ្ឋកិច្ចអាស៊ី នៅសតវត្សរ៍ទី២១ នេះ ត្រូវបានគេចាត់ទុកថា ជាក្បាលម៉ាស៊ីនទី២សម្រាប់ជំរុញកំណើន សេដ្ឋកិច្ចពិភពលោកនៅពេលអនាគត ។ នេះជាការប្រែប្រួលថ្មី ។

២/- ការកើនឡើងនៃនិន្នាការធ្វើសមាហរណកម្មវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាម តំបន់នានា ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) និងជំរុញការនាំចេញ របស់ខ្លួន ។

៣/- ការពង្រឹងនិងអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ខណៈពេលដែលនិន្នាការនៃការធ្វើសេរី-ភាវូបនីយកម្មនៅក្នុងតំបន់អាស៊ីបានកើនឡើង ។ វិស័យធនាគារនិងហិរញ្ញវត្ថុ បានដើរ តួនាទីស្នូលក្នុងការជំរុញនិងអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការកៀងគរប្រាក់សញ្ញ័យនៅទំនេរ សម្រាប់យកទៅពង្រីកគម្រោងវិនិយោគ ។

៤/- តម្រូវការប្រើប្រាស់និងការវិនិយោគនៅអាស៊ីបានកើនឡើង ។ ការកើនឡើងនេះ គឺជាមូលដ្ឋានទី២នៃភាពខ្លាំងរបស់សេដ្ឋកិច្ចអាស៊ី បន្ទាប់ពីការនាំចេញរបស់អាស៊ី ។

៥/- ការបង្កើតនិងពង្រឹងប្រព័ន្ធសុវត្ថិភាពហិរញ្ញវត្ថុនិងសង្គម (FSSN) ដើម្បីទាក់ទាញ ការវិនិយោគ ពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

៦/- ការកើនឡើងនៃតួនាទីអាស៊ីខាងផ្នែកការសម្រេចចិត្ត និងការគ្រប់គ្រងក្នុងស្ថាប័ន ហិរញ្ញវត្ថុអន្តរជាតិ ដូចជា IMF World Bank និង IFC ដើម្បីជួយប្រទេសកំពុងអភិវឌ្ឍន៍ ។

៧/- ការខិតខំពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ លើផ្នែកបច្ចេកទេស សេដ្ឋកិច្ច និងនយោបាយរវាងប្រទេសនៅក្នុងតំបន់ ដើម្បីសម្របសម្រួលការអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិ និងការកែទម្រង់ក្របខ័ណ្ឌច្បាប់និងក្របខ័ណ្ឌគោលនយោបាយ ឲ្យស្រប តាមនិយាមអន្តរជាតិ វិន័យទីផ្សារ និងយន្តការសេដ្ឋកិច្ច ។

ត្រង់ចំណុចនេះខ្ញុំចង់បញ្ជាក់ថា បន្ទាប់ពីទទួលរងនូវវិបត្តិសេដ្ឋកិច្ចនិងទីផ្សារហិរញ្ញវត្ថុពិភពលោកនាពេលថ្មីៗនេះ សេដ្ឋកិច្ចអាស៊ីមានភាពរឹងមាំ និងក្លាយជាក្បាលម៉ាស៊ីនទី២ក្នុងការជំរុញកំណើនសេដ្ឋកិច្ចពិភពលោក ។ ថ្វីត្បិតតែបច្ចុប្បន្ននេះ កំណើនសេដ្ឋកិច្ចក្នុងតំបន់និងពិភពលោកបានរើបឡើងវិញមែន ប៉ុន្តែនៅមានភាពផុយស្រួយនៅឡើយទេ ។ ដូច្នេះ ចំពោះវិស័យហិរញ្ញវត្ថុ អាជ្ញាធរត្រូវប្រកាន់យកនូវវិធានការប្រុងប្រយ័ត្ន មានជាអាទិ៍ការពង្រឹងការត្រួតពិនិត្យសុវត្ថិភាពនិងភាពរឹងមាំនៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងការធ្វើកំណែទម្រង់ក្របខ័ណ្ឌគោលនយោបាយ និងបទប្បញ្ញត្តិចាំបាច់មួយចំនួន រួមមាន ៖

- ការអនុវត្តយុទ្ធសាស្ត្រចេញពីវិបត្តិ (Exit Strategy) : ដោយកាត់បន្ថយអន្តរាគមន៍របស់រដ្ឋាភិបាលជាបណ្តើរៗ ដើម្បីការពារកុំឲ្យមានឱនភាពថវិកាខ្លាំង ហើយទុកឲ្យទីផ្សារដំណើរការដោយខ្លួនឯងវិញ ។

- ការធ្វើកំណែទម្រង់ក្របខ័ណ្ឌបទប្បញ្ញត្តិចាំបាច់មួយចំនួន សំដៅពង្រឹងស្ថិរភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ក្រោមរូបភាពពីរគឺ ៖ *ទី១/-* អភិបាលកិច្ចល្អនិងសុខភាពរបស់គ្រឹះស្ថានធនាគារនីមួយៗ (Microprudential) តាមរយៈការបង្កើនដើមទុន ដើម្បីឲ្យគ្រឹះស្ថានធនាគារនោះ មានប្រភពទុនគ្រប់គ្រាន់សម្រាប់ទប់ទល់នឹងហានិភ័យ ។ *ទី២/-* ពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុទាំងមូល (Macroprudential) ដើម្បីទប់ទល់ហានិភ័យជាប្រព័ន្ធ តាមរយៈការវិភាគលើភាពទន់ខ្សោយនៃប្រព័ន្ធធនាគារ (Stress Testing) ក្នុងគោលដៅតាមដានស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ (Macrofinancial Stability) ។

ដើម្បីជ្រាបពីបញ្ហាថ្មីៗដែលកើតមានក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងការប្រែប្រួលតួនាទីអាស៊ីក្នុងការជំរុញកំណើនសេដ្ឋកិច្ចពិភពលោកបន្ថែមទៀត ខ្ញុំស្នើសុំឲ្យ ឯកឧត្តម ស៊ុំ សន្និសិទ្ធ ធ្វើបទឧទ្ទេសនាមស្តីពី **ការប្រែប្រួលតួនាទីធនាគារកណ្តាល ក្រោយវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ឆ្នាំ២០០៨** ជូនថ្នាក់ដឹកនាំ មន្ត្រីត្រួតពិនិត្យ សេដ្ឋវិទូ អ្នកសិក្សាស្រាវជ្រាវ និងមន្ត្រីប្រតិបត្តិរបស់យើងនៅថ្ងៃស្អែកនេះ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ចំពោះអង្គសន្និបាតរបស់យើងវិញក៏បានផ្តល់ខ្លឹមសារសំខាន់ៗ ទាក់ទងនឹងតួនាទីនិងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការដឹកនាំនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃ ការងារសវនកម្មផ្ទៃក្នុងនិងអភិបាលកិច្ចល្អ ការពង្រឹងជំនឿទុកចិត្តលើប្រាក់រៀល

ការបណ្តុះបណ្តាលធនធានមនុស្ស ការងារអគ្គលេខា ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងការត្រួតពិនិត្យសុខភាពប្រព័ន្ធធនាគាររួចហើយ ។ ជារួម នៅឆមាសទី១ ឆ្នាំ២០១០ នេះ យើងអាចរក្សាបាននូវស្ថិរភាពថ្លៃ និងរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់ ឆ្ពោះទៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ តាមការវាយតម្លៃដោយប្រុងប្រយ័ត្នរបស់រដ្ឋាភិបាលថា នៅឆ្នាំ២០១០ នេះ កំណើនសេដ្ឋកិច្ចកម្ពុជានឹងកើនប្រមាណ ៥% ធៀបនឹង ០,១% នៅឆ្នាំ២០០៩ ។

ដើម្បីបន្តចូលរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបន្តអនុវត្តទិសដៅការងាររបស់ធនាគារជាតិនៃកម្ពុជាឲ្យទទួលបានជោគជ័យ និងកាន់តែមានប្រសិទ្ធភាពថែមទៀត ខ្ញុំសូមលើកឡើងនូវមតិខ្លះបន្ថែមទៀត ដើម្បីជាការផ្តាំផ្ញើដល់មន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាលនិងនៅសាខារាជធានី-ខេត្ត អំពីអ្វីដែលធនាគារជាតិនៃកម្ពុជាត្រូវធ្វើនាពេលអនាគត ដូចតទៅ ៖

**១/-ការពង្រឹងប្រព័ន្ធធនាគារ** : លោកជំទាវ គាល់ ណៃអ៊ីម បានរាយការណ៍ជូនអង្គសន្និបាត អំពីស្ថានភាពបច្ចុប្បន្ននៃវិស័យធនាគារ និងវិធានការនានា ដែលធនាគារជាតិនៃកម្ពុជាអនុវត្ត ដើម្បីពង្រឹងប្រព័ន្ធធនាគារនៅកម្ពុជាឲ្យកាន់តែមានភាពរឹងមាំ និងប្រសិទ្ធភាពខ្ពស់ ។ ដើម្បីឲ្យការអនុវត្តកាន់តែមានប្រសិទ្ធភាពថែមទៀត យើងបន្តកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិ និងពង្រឹងសមត្ថភាពត្រួតពិនិត្យ ឲ្យស្របតាមការវិវត្តរីកចម្រើននៃប្រព័ន្ធធនាគារបច្ចុប្បន្ន និងជំរុញឲ្យមានការិយាល័យឥណទាននៅកម្ពុជា ។

**២/- ចំពោះវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា** មានការរីកចម្រើនយ៉ាងខ្លាំង ។ យើងត្រូវខិតខំបង្កលក្ខណៈងាយស្រួលតាមផ្លូវច្បាប់ ដើម្បីឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលរឹងមាំអាចបំពេញលក្ខខណ្ឌ ដើម្បីអាចទទួលប្រាក់បញ្ញើពីសាធារណជនបាន ស្របតាមតម្រូវការទីផ្សារ និងខិតខំបង្កើតកម្មវិធីផ្សព្វផ្សាយ ដើម្បីឲ្យប្រជាជនយល់ដឹងពីសារៈប្រយោជន៍នៃការប្រើប្រាស់ឥណទានខ្នាតតូច ។ យើងត្រូវបន្តពង្រឹងកិច្ចសហការជាមួយស្ថាប័នជាតិ-អន្តរជាតិ ដើម្បីពង្រឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុជនបទឲ្យកាន់តែទូលំទូលាយ ។

**៣/- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ** : ធនាគារជាតិនៃកម្ពុជាត្រូវបន្តគ្រប់គ្រងទុនបម្រុងអន្តរជាតិដោយប្រុងប្រយ័ត្ន ដោយឈរលើគោលការណ៍សុវត្ថិភាព សាច់ប្រាក់ងាយស្រួល

និងចំណូល ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជា ត្រូវរក្សាកម្រិតទុនបម្រុងអន្តរជាតិរបស់ខ្លួន យ៉ាងតិចស្មើនឹង ៣,៥ខែ នៃការនាំចូល ។

**៤/- ចំពោះការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** : យើងត្រូវបន្តពង្រឹងការអនុវត្តច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ពង្រឹងកិច្ចសហការជាមួយសហគមន៍ជាតិ-អន្តរជាតិបន្ថែមទៀត សំដៅរួមចំណែកការពារ ទប់ស្កាត់ និងប្រឆាំងរាល់សកម្មភាពនៃការលាងសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុតំបន់និងពិភពលោក ។

**៥/- ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច** : ឯកឧត្តម ប៉ាល់ ប៊ុយបុណ្ណាង បានជម្រាបជូននិងពន្យល់ច្បាស់លាស់ពីខ្លឹមសារនិងបច្ចេកទេស ។ ខ្ញុំសូមឯកភាព ។ ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ទាក់ទងនឹងការធ្វើសវនកម្ម ដើម្បីពង្រឹងប្រតិបត្តិការរបស់ធនាគារកណ្តាល និងសុខភាពធនាគារជាតិនៃកម្ពុជាឲ្យមានប្រសិទ្ធភាពខ្ពស់ ។ ដូច្នេះ ដើម្បីដំណើរការងារនេះឲ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់ គឺទាមទារឲ្យយើងរៀបចំផែនការជាមុន និងមន្ត្រីមានសមត្ថភាពជំនាញ ប្រកបដោយការតស៊ូព្យាយាម ភាពស្មោះត្រង់ គោរពវិន័យនិងប្រកាន់ភ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះការងារ ។ ខ្ញុំសូមស្នើសុំឲ្យមានការបន្តចុះតាមដានការអនុវត្តតាមអនុសាសន៍ដែលបានលើកឡើង និងពង្រឹងការងារអធិការកិច្ចនៅសាខាធនាគារជាតិនៃកម្ពុជា ។

**៦/- ការងារអគ្គលេខា** : ការងារនេះ ឯកឧត្តម ថា យ៉ាវ បានអធិប្បាយនិងពន្យល់ច្បាស់លាស់ហើយ ។ ខ្ញុំសូមឯកភាពតាមអនុសាសន៍ទាំងនេះ ដូច្នេះ ដើម្បីអនុវត្តការងារនេះឲ្យមានប្រសិទ្ធភាព តម្រូវឲ្យមន្ត្រីទាំងអស់ប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ សីលធម៌ វិន័យការងារ មានស្មារតីទទួលខុសត្រូវខ្ពស់ និងគោរពតាមការចាត់តាំង ព្រមទាំងពង្រឹងប្រព័ន្ធសុវត្ថិភាពនិងសន្តិសុខ ។

**៧/- កិច្ចសហប្រតិបត្តិការអន្តរជាតិ** : យើងត្រូវបន្តសហការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ មជ្ឈមណ្ឌលបណ្តុះបណ្តាលប្រចាំតំបន់ និងធនាគារកណ្តាលបរទេសក្នុងតំបន់និងពិភពលោក ដើម្បីបណ្តុះបណ្តាលពីឯកទេសដល់មន្ត្រីជំនាញ ផ្លាស់ប្តូរបទពិសោធន៍គ្នា និងធ្វើការស្រាវជ្រាវអំពីដំណោះស្រាយចំពោះបញ្ហាប្រឈមនានា ដែលកំពុងតែកើតឡើងនៅក្នុងតំបន់និងពិភពលោកនាពេលបច្ចុប្បន្ន ។

**៨/- ការងារគ្រប់គ្រងនិងបណ្តុះបណ្តាលមន្ត្រីបុគ្គលិក** : ឯកឧត្តម ស៊ុំ សន្និសិទ្ធ បានអធិប្បាយនិងពន្យល់ច្បាស់លាស់ហើយ ។ ខ្ញុំសូមឯកភាពតាមមតិទាំងនេះ ។ ខ្ញុំក៏សូមបញ្ជាក់ថា ធនធានមនុស្ស គឺជាកត្តាកំណត់ជោគជ័យនៃការងាររបស់យើងលើគ្រប់ផ្នែក ។ ការអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា គឺជាការងារដែលត្រូវធ្វើជាប្រចាំនៅទីកន្លែងទាំងផ្នែកជំនាញនិងផ្នែកគុណធម៌ ។ ធនាគារជាតិនៃកម្ពុជាបន្តបញ្ជូនមន្ត្រីបុគ្គលិក ទៅចូលរួមវគ្គសិក្សារយៈពេលវែងនិងខ្លីនៅបរទេស ដើម្បីលើកកម្ពស់សមត្ថភាពមុខជំនាញឯកទេស ភាសាបរទេស វិន័យការងារ និងស្មារតីទទួលខុសត្រូវចំពោះការងារ ជាពិសេស ស្មារតីចេះអភិវឌ្ឍខ្លួនឯងនៅកន្លែងការងារ និងសម្រិតសម្រាំងជ្រើសរើសមន្ត្រីថ្មីចូលបម្រើការងារតាមរយៈការប្រឡងប្រជែង ។

**៩/- សមាគមមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា** បានបំពេញភារកិច្ចល្អប្រសើរហើយ ។ ឯកឧត្តម ថា យ៉ាវ ក៏បានរាយការណ៍ជូនអង្គសន្និបាតច្បាស់លាស់ហើយ ។ ខ្ញុំសូមបញ្ជាក់ជូនថា សំខាន់គឺសមាគមត្រូវបន្តពង្រឹងសាមគ្គីភាពផ្ទៃក្នុងជាភាតរភាព និងជួយឧបត្ថម្ភគ្នាទៅវិញទៅមកក្នុងពេលមានការលំបាក ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីស្នេហា !**

ខ្លឹមសារដែលខ្ញុំបានលើកឡើងខាងលើនេះ សុទ្ធតែជាការងាររបស់ធនាគារជាតិនៃកម្ពុជា ដែលយើងត្រូវអនុវត្តសម្រាប់រយៈពេលខ្លីនិងវែងនាពេលអនាគត ក្នុងគោលដៅបន្តពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធធនាគារទាំងមូល ឲ្យកាន់តែមានលក្ខណៈទំនើបទាំងផ្នែកសេវានិងផលិតផល និងមានលក្ខណៈសមាហរណកម្មខ្ពស់ទៅក្នុងតំបន់ មានសុវត្ថិភាព ប្រសិទ្ធភាព និងទទួលបានការជឿទុកចិត្តពីសាធារណជនទូទៅបន្ថែមទៀត ។

ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាទាំងអស់ នឹងបន្តការខិតខំប្រឹងប្រែងអនុវត្តទិសដៅភារកិច្ចទាំងឡាយ ឲ្យសម្រេចបានជោគជ័យប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមចំណែកពង្រឹងប្រព័ន្ធធនាគារ និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឲ្យមានការរីកចម្រើនប្រកបដោយចីរភាព ។

មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើនូវមតិមួយចំនួនដូចខាងក្រោម ៖

១/- ត្រូវយកស្មារតីនៃអង្គសន្និបាតរបស់យើងទៅផ្សព្វផ្សាយបន្ត និងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់

២/- បន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងប្រព័ន្ធធនាគារឲ្យកាន់តែមានសុខភាពល្អ មានប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មខ្ពស់។

៣/- បន្តអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានថ្លែងក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ នៅសាលសន្និសីទចតុមុខ កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ កន្លងមក ឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

៤/- ការបណ្តុះបណ្តាលនិងការចាត់តាំងមន្ត្រីបុគ្គលិក ត្រូវធ្វើឡើងដោយផ្អែកលើតម្រូវការចាំបាច់ សមត្ថភាពការងារ បទពិសោធន៍ការងារ និងគុណធម៌ ។ ដើម្បីពង្រឹងរចនាសម្ព័ន្ធចាត់តាំងនិងការគ្រប់គ្រង ការចាត់តាំងមន្ត្រីបុគ្គលិក គឺត្រូវធ្វើឡើងជាលក្ខណៈផ្លាស់ប្តូរភារកិច្ចគ្នា ពីកន្លែងមួយទៅកន្លែងមួយ ឬពីទីស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត ស្របទៅតាមតម្រូវការការងារជាក់ស្តែង សំដៅពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង និងប្រសិទ្ធភាពការងារឲ្យកាន់តែប្រសើរឡើងថែមទៀត។

ក្រៅពីការងារស្នូល គឺយើងត្រូវរៀបចំកសាងសារមន្ទីររូបិយវត្ថុជាតិមួយ ដើម្បីចងក្រងប្រវត្តិនៃការរីកចម្រើននៃប្រព័ន្ធធនាគារ និងរចនាសម្ព័ន្ធរូបិយវត្ថុនៅកម្ពុជា ទុកសម្រាប់សាធារណជនទូទៅសិក្សាស្វែងយល់ពីប្រវត្តិរូបិយវត្ថុខ្មែរយើង ។

៥/- ធនាគារជាតិនៃកម្ពុជាកំពុងត្រៀមលក្ខណៈធ្វើជាម្ចាស់ផ្ទះ ដើម្បីរៀបចំ : *១)*- កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ (EXCO) លើកទី៩ នៅថ្ងៃទី១៩-២១ ខែមករា ឆ្នាំ២០១១ នៅទីក្រុងភ្នំពេញ និង *២)*- កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone) លើកទី១៨ ពីថ្ងៃទី២៥-២៧ ខែឧសភា ឆ្នាំ២០១១ នៅខេត្តសៀមរាប ។ កិច្ចប្រជុំនេះមានសារៈសំខាន់ណាស់ ព្រោះជាវេទិកាសហប្រតិបត្តិការតំបន់និងអន្តរជាតិ ដើម្បីបង្ហាញពីកិត្យានុភាពនិងតួនាទីយ៉ាងសកម្មរបស់កម្ពុជា ជាពិសេសធនាគារជាតិនៃកម្ពុជា ក្នុងសហគមន៍អន្តរជាតិ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលដ៏ល្អ និងបានកសាងប្រព័ន្ធធនាគារឲ្យទទួលបានជំនឿទុកចិត្តពីសាធារណជនជាតិ និងអន្តរជាតិឲ្យកាន់តែប្រសើរឡើង ប្រកបដោយភាពស្មោះត្រង់និងមានវិជ្ជាជីវៈពិតប្រាកដ ។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវការអបអរសាទរនិងថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមអង្គសន្និបាតតាំងពីដើម រហូតដល់ចប់ និងសូមជូនពរឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**